# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/៩០៦៣

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្ត វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលសរសេរជាអក្សរកាត់ថា **គ.ជ.រ.** ជាយន្តការរបស់ រាជរដ្ឋាភិបាល ក្នុងការជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និង សមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ការលើកកម្ពស់ប្រសិទ្ធភាព ការងារ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី២
## ភារកិច្ចរបស់ គ.វ.រ.

**មាត្រា២ .-**

**គ.វ.រ.** មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
- ដាក់ចេញនូវវិធានការចាំបាច់ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សូចនាករសមិទ្ធកម្មសម្រាប់ការអនុវត្តវិធានការគន្លឹះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងភាគីពាក់ព័ន្ធ លើការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីជំរុញនិងគាំទ្រការអនុវត្តវិធានការគន្លឹះ
- ធានាសង្គតិភាពនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ជាមួយការងារកែទម្រង់ក្នុងវិស័យផ្សេងៗរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី៣
## សមាសភាពនិងរចនាសម្ព័ន្ធរបស់ គ.វ.រ.

**មាត្រា៣ .-**

**គ.វ.រ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៨- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៩- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | អនុប្រធានប្រចាំការ |
| ១០- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១៨- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ១៩- រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ២០- រដ្ឋមន្ត្រីក្រសួងអធិការកិច្ច | សមាជិក |
| ២១- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ២២- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ២៣- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ២៤- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ២៥- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ២៦- រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៧- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ២៨- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៩- រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៣០- រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន | សមាជិក |
| ៣១- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក ។ |

សមាសភាពជាក់ស្តែងនៃ **គ.ទ.រ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ទ.រ.** អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពបន្ថែម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤ ._**

**គ.ទ.រ.** អាចមានអនុគណៈកម្មាធិការ និង/ឬក្រុមការងារ ដើម្បីបម្រើការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា២ តាមការចាំបាច់។ អនុគណៈកម្មាធិការ និង/ឬក្រុមការងាររបស់ **គ.ទ.រ.** ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ គ.ទ.រ.

**មាត្រា៥ ._**

**គ.ទ.រ.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់៣(បី)ខែម្តង តាមការអញ្ជើញរបស់ប្រធាន។

តាមការអញ្ជើញរបស់ប្រធានឬតំណាងដែលទទួលការប្រគល់សិទ្ធិពីប្រធាន អនុប្រធាននិងសមាជិក **គ.ទ.រ.** ត្រូវចូលរួមប្រជុំឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមានឬមានធុរៈ។

**គ.ទ.រ.** ប្រើត្រារបស់រាជរដ្ឋាភិបាល សម្រាប់ដំណើរការការងារ។

**មាត្រា៦ ._**

ប្រធាន **គ.ទ.រ.** អញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំនិងបំពេញការងារស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៧ ._**

**គ.ទ.រ.** និងអនុគណៈកម្មាធិការ ព្រមទាំងក្រុមការងារ អញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំពិគ្រោះយោបល់ តាមការចាំបាច់។

**មាត្រា៨ .–**

ក្រសួងមុខងារសាធារណៈបំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ជ.រ.**។

**មាត្រា៩ .–**

តួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខ័ណ្ឌជាលេខាធិការដ្ឋាន **គ.ជ.រ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ជ.រ.

**មាត្រា១០ .–**

ប្រភពធនធានសម្រាប់ទ្រទ្រង់ **គ.ជ.រ.** មាន ថវិកាជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀតដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .–**

អាណត្តិរបស់ **គ.ជ.រ.** នឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានបញ្ចប់។

**មាត្រា១២ .–**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ថ្ងៃ សៅរ៍ ៩រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បន្ទាប់**
**ប្រមុខរដ្ឋស្តីទី**

ពរក.២៣០៩.៤១០

ស.រ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**